# វង់ភ្លេងមហោរី

ប្រទេសកម្ពុជាមានអំណោយផលធម្មជាតិដ៏ឧត្តុង្គឧត្តម ផ្តល់ដល់ជីវិតរស់នៅនៃប្រជាជនខ្មែរប្រកបដោយទំនៀមទម្លាប់ប្រពៃណីដ៏ល្អថ្លៃថ្លា។ ក្នុងនោះធម្មជាតិបានផ្តល់នៅវត្ថុធាតុដើមជាច្រើនដូចជា ដី ឈើ ឫស្សី វល្លិ៍ ដែក ស្បែកសត្វ ឆ្អឹង ក្អុក និងសំបកខ្យងជាដើម ដែលអាចឱ្យមនុស្សទាញយកមកកែច្នៃប្រើប្រាស់ទៅតាមតម្រូវការប្រចាំថ្ងៃ និងផលិតជាឧបករណ៍តន្ត្រីផ្សេងៗដើម្បីជាការកែកម្សាន្ត។ បុព្វបុរសខ្មែរបានច្នៃប្រឌិតប្រកបដោយទេពកោសល្យខ្ពស់នូវឧបករណ៍តន្ត្រីដ៏សម្បូណ៌បែបមានស្នែង ត្រែ ប៉ី ខ្លុយ ស្រឡៃ ព្ទយ គែន ពិណ ទ្រ ឃឹម ម៉ិម ខ្សែ១ ក្រពើ ចាប៉ី រនាត គង សម្ភោរ ស្គរ ឆាប និងឈឹង។ល។

ឧបករណ៍តន្ត្រីទាំងនេះ ជាទូទៅគេច្រើនប្រគំលេងនៅក្នុងវង់តន្ត្រីជាប្រភេទអារក្ខ អាពាហ៍ពិពាហ៍ អាយ៉ៃ ឆៃយ៉ាំ ពិណពាទ្យ និងមហោរី ជាដើម។ "**មហោរី**" សំដៅទៅលើចម្រៀង និងវង់តន្ត្រី។ ពាក្យ "**មហោរី**" ជាឈ្មោះរបស់សត្វស្លាបដែលយើងហៅថា "**សត្វមហោរី**"។ បើយើងនិយាយអំពីវង់តន្ត្រីវិញ គឺសំដៅយកវង់តន្ត្រីខ្នាតតូច ឬធំ ដែលមានឧបករណ៍រនាតឯក រនាតធុង ទ្រឆេ ទ្រសោតូច ទ្រសោធំ ទ្រអ៊ូ ខ្លុយ ឃឹម ក្រពើ ថូន រមនា ឈឹង និងអ្នកច្រៀង។ ឧបករណ៍នៅក្នុងវង់តន្ត្រីមហោរី អាចមានច្រើន ឬតិចទៅតាមលទ្ធភាព និងចំណង់ចំណូលចិត្តរបស់តន្ត្រីករ ឬអ្នកឧបត្ថម្ភកម្មវិធី។ ឧទាហរណ៍ វង់តន្ត្រីមហោរីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ មានបញ្ចូលទាំងទ្រកណ្តាល និងទ្រធំទៀតផង។

ចំពោះវង់តន្ត្រីខ្មែរឯទៀតដែលមានតួនាទីបម្រើឲ្យសាសនា ឬពិធីផ្សេងៗ ដូចជាវង់តន្ត្រីអារក្ខ អាពាហ៍ពិពាហ៍ ប៉ីកែវ គងស្គរ ជាដើម។ វង់តន្ត្រីមហោរីបម្រើសកម្មភាព ឬព្រឹត្តិការណ៍ក្រៅសាសនា។ វង់នេះជាវង់តន្ត្រីដែលមានចារិតលក្ខណៈ និងសូរស្រោលដែលគេច្រើនយកទៅប្រើកំដរល្ខោនមហោរី និងរបាំប្រពៃណីខ្មែរ មានរបាំក្រាប់ របាំនេសាទ របាំអង្រែ ឬរបាំច្រូតស្រូវជាដើម។ ជាពិសេសនៅតាមទីជនបទស្រុកស្រែចម្ការ ក៏ដូចជាទីក្រុងគេតែងតែឮសូរតន្ត្រីមហោរីលេងនៅពេលបាយល្ងាច ឬក្រោយពេលបាយដើម្បីជាការកែកម្សាន្ត។

បទភ្លេងមហោរីមានដូចជា អណ្តើកស៊ីត្រកួន ខ្យល់បក់ដើមភ្នំ ស្រីលាវតូច ស្រីបុកស្រូវ ដំណើរខ្មែរ ផ្ទៃស្រុកខ្មែរ ខ្មែរច្រូតស្រូវ ខ្មែរក្រងផ្កា ឡាវគន់មើលព្រះច័ន្ទ ភូមាចាក់កង្កែប ចិនចុះទូក និងបារាំងស្រាវពួរ ជាដើម។

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

## មហោរីសម័យ ឬមហោរីក្លាយ

ប្រទេសកម្ពុជាយើងក៏មានវង់តន្ត្រីមហោរីសម័យ ឬមហោរីក្លាយមួយដែរ។ វង់តន្ត្រីនេះគឺគេរួមបញ្ចូលនូវឧកបករណ៍តន្ត្រីបស្ចឹមប្រទេសមានបង់ហ្សូ វីយ៉ូឡុង ខ្ទុយដែក អាក់គ័រដេអុង និងអ៊ិរ៉ក ជាដើម ដោយលេងបទដូចខាងលើនេះដែរ។

ចំពោះការលេងភ្លេងនេះ គឺគេច្រើនអ្នកច្រៀង ច្រៀងមួយល្បះ កំដរដោយថូន រមនា និងឈឹង រួចហើយគេឱ្យអ្នកភ្លេងទទួលមួយចប់ភ្លេង ឆ្លាស់គ្នារហូតដល់ចប់បទ។





អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង